# សាធារណរដ្ឋប្រជាមានិតកម្ពុជា-រដ្ឋកម្ពុជា (1979-1991) ព្រះរាជាណាចក្រកម្ពុជា 1993

របបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប៉ុលពតបានធ្វើឲ្យប្រទេសកម្ពុជាធ្លាក់ដល់ក្រោមសូន្យ និង បានធ្វើឲ្យប្រជាជនខ្មែរគ្មានទំនុកចិត្ត បាក់ស្បាត តក់ស្លុត រស់ទាំងអស់សង្ឃឹម។ ថ្ងៃទី7 មករា 1979 ជាថ្ងៃរំដោះប្រជាជនកម្ពុជា អោយរួចផុតពីរបបឃោរឃៅព្រៃផ្សៃប្រល័យពូជសាសន៍ ដ៏ខ្មៅងងឹត។

## ១. ការបង្កើតរណសិរ្សសង្គ្រោះជាតិកម្ពុជា

របបកម្ពុជាប្រជាធិបតេយ្យបានបង្ខំប្រជាជនកម្ពុជាអោយធ្វើការជាទំងន់បង្អត់អាហារ គ្មានថ្នាំព្យាបាល ខ្វះសម្លៀកបំពាក់ គ្មានជំរកស់នៅសមរម្យ បបិទសិទ្ធសេរីភាពគ្រប់យ៉ាង ពិសេសពួកឃាតករអាវខ្មៅបានសម្លាប់ប្រជាជនកម្ពុជាដោយគ្មានកំហុស។ របបនេះប្រៀបដូចគុកឥតជញ្ជាំង ឬ ឋាននរក។ ដោយឃើញអំពើព្រៃផ្សៃបែបនេះហើយ កម្មាភិបាលខ្មែរក្រហមមួយចំនួនបានចេញមុខប្រឆាំង ប៉ុន្តែត្រូវមេខ្មែរក្រហមយកទៅសម្លាប់ចោល។

នៅថ្ងៃទី2 ខែធ្នូ ឆ្នាំ 1978 មហាសន្និបាតបានសម្រេចជាឯកច្ឆន្ទបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដើម្បីប្រយុទ្ធប្រឆាំង និង អំពើរប្រល័យពូជសាសន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ។

កងកម្លាំងប្រដាប់អាវុធរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដោយមានជំនួយពីកងទ័ពវៀតណាម និង ទទួលការគាំទ្រពីប្រជាជនកម្ពុជាបានរួមកម្លាំងគម្ទេចកងទ័ពខ្មែរក្រហមរំដោះប្រជាជនកម្ពុជាបានជាស្ថាពរនៅថ្ងៃទី 7 មករា 1979។

## ២. រចនាសម្ព័ន្ធគ្រប់គ្រងឆ្នាំ 1979-1981

- សមមិត្ត ហេង សំរិន ជាប្រធានរដ្ឋ ឬ ប្រមុខរដ្ឋ និង ជាប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា
- សមមិត្ត ប៉ែន សុវណ្ណ អនុប្រធានក្រុមប្រឹក្សា ប្រជាជនបដិវត្តន៍កម្ពុជា និង ជារដ្ឋមន្ត្រីក្រសួងការពារជាតិ(1979-1981) និង ជានាយករដ្ឋមន្ត្រី
- សមមិត្ត ជា ស៊ីម ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- សមមិត្ត ហ៊ុន សែន ជារដ្ឋមន្ត្រីក្រសួងការបរទេស
- សមមិត្ត កែវ ចិន្តា ជារដ្ឋមន្ត្រីឃោសនាការ ពត៌មាន និងវប្បធម៌
- សមមិត្ត ចាន់ វ៉ែន ជាមន្ត្រីក្រសួងអប់រំ
- សមមិត្ត ចាន់ ស៊ី ជានាយករដ្ឋមន្ត្រីក្រោយចាប់ខ្លួន ប៉ែន សុវណ្ណ។

## ៣. នយោបាយបង្រួបបង្រួមជាតិ

ក្រោយរំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមមេដឹកនាំធំៗ និង កងទ័ពកម្ពុជាប្រជាធិបតេយ្យបានភៀសខ្លួនទៅបង្កសង្គ្រាមនៅតាមព្រំដែនកម្ពុជា ថៃ។ មានក្រុមពីរទៀតគឺ ក្រុមសេរីការ របស់លោក សឺន សាន និង ក្រុមរាជានិយម របស់ សម្តេច នរោត្តមសីហនុ បានរួមគ្នាប្រឆាំងនិង រដ្ឋាភិបាល រដ្ឋកម្ពុជា។

នៅថ្ងៃទី 23 តុលា 1991 កិច្ចចរចាសន្តិភាពនាទីក្រុង ប៉ារីស រវាងគូរវិវាទខ្មែរបានប្រារព្ធឡើងនិង ទទួលលទ្ធផលយ៉ាងល្អប្រសើរ ដោយ តំណាងភាគីជម្លោះបានចាប់ដៃគ្នាយល់ព្រមធ្វើការបោះឆ្នោតជាសកលក្រោមជំនួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ហៅកាត់ អ៊ុន តាក់ នៅខែតុលា ឆ្នាំ 1993 បានបោះឆ្នោតនៅកម្ពុជា។

នៅថ្ងៃទី24 កញ្ញា 1993 រដ្ឋធមនុញ្ញថ្មីត្រូវបានប្រកាសអោយប្រើជាទូទៅហើយប្រទេសត្រូវបានចារឹកឈ្មោះថា “ ព្រះរាជាណាចក្រកម្ពុជា ” ដែលគ្រងរាជ្យជាលើកទី2 របស់សម្តេចនរោត្តម សីហនុ។

រៀបរៀងដោយ អ៊ុក ភារិន្ទ